សម្រាប់ Community Solutions, Inc. Members (សមាជិក)

# របៀបទទួលបានការដឹកជញ្ជូនសម្រាប់សេវាថែទាំសុខភាព

អ្វីដែលអ្នកត្រូវដឹងអំពីការដឹកជញ្ជូនផ្នែកវេជ្ជសាស្ត្រជាប្រចាំ



www.healthnet.com



# អ្នកត្រូវបានធានារ៉ាប់រង សម្រាប់ការធ្វើដំណើរទាក់ទង នឹងការថែទាំសុខភាព

*គម្រោង Health Net Medi-Cal របស់អ្នករ៉ាប់រងលើការធ្វើដំណើរ នៅពេលដែលអ្នកត្រូវការការថែទាំសុខភាព និងសេវាកម្ម ដែលត្រូវបានគេស្គាល់ផងដែរថាជា* ***ការដឹកជញ្ជូនផ្នែកវេជ្ជសាស្ត្រជាប្រចាំ។***

## របៀបដែលអត្ថប្រយោជន៍នេះដំណើរការ

ប្រភេទនៃការជិះដែលអ្នកអាចកំណត់ពេលរួមមាន:

- ការដឹកជញ្ជូនវេជ្ជសាស្ត្រមិនសង្គ្រោះបន្ទាន់ (NEMT) (ប្រភេទនៃការដឹកជញ្ជូននេះរួមមានសមាជិកដែលមិនអាចដើរបានដោយហេតុផលណាមួយ ឬមិនអាចឈរ ឬដើរដោយគ្មានជំនួយ រួមទាំងអ្នកដែលប្រើឧបករណ៍ជំនួយការដើរ ឬឈើច្រត់)
  - យានជំនិះដែលមានរទេះរុញ និងគ្រែរុញ។
  - ទូរសព្ទមក 48 ម៉ោងជាមុន។
- ការដឹកជញ្ជូនមិនមែនវេជ្ជសាស្ត្រ (NMT)
  - រថយន្ត ឡានវែន តាក់ស៊ី Rideshare និងមធ្យោបាយធ្វើដំណើរសាធារណៈ។
  - ទូរសព្ទមក 24 ម៉ោងជាមុន។
  - Rideshare មកដល់ក្នុងរយៈពេលមួយម៉ោង។

អ្នកអាចកំណត់ពេលធ្វើដំណើរទៅកន្លែងណាមួយដែលផ្តល់សេវាថែទាំវេជ្ជសាស្ត្រ ឬសេវាថែទាំសុខភាព។ មិនមានដែនកំណត់លើរយៈចម្ងាយទេ។

*សូមចំណាំ៖ ការធ្វើដំណើរតាមមធ្យោបាយធ្វើដំណើរសាធារណៈត្រូវកំណត់ពេលឱ្យបាន 5 ថ្ងៃជាមុន។ ការធ្វើដូច្នេះទើបយើងអាចផ្ញើសំបុត្រឡានក្រុង និង/ឬថូខិនទៅអ្នកបាន។*

ជាការរំលឹក អ្នកផ្តល់សេវារបស់អ្នកត្រូវតែបំពេញ **Physician Certification Statement** (ទម្រង់បែបបទវិញ្ញាបនបត្រគ្រូពេទ្យ) **(PCS)** សម្រាប់ **NEMT**។ សូមទាក់ទងអ្នកផ្តល់សេវារបស់អ្នក ដើម្បីធានាថាទម្រង់ **PCS** ត្រូវបានបំពេញ ហើយផ្ញើទៅកាន់ **Health Net**។

**ប្រសិនបើអ្នកត្រូវការសង្គ្រោះបន្ទាន់ផ្នែកវេជ្ជសាស្ត្រ សូមទូរសព្ទទៅ 911 ភ្លាមៗ។**

### មិនមានការចំណាយបន្ថែមសម្រាប់សេវាកម្មនេះទេ។

ប្រើអត្ថប្រយោជន៍នេះ នៅពេលដែលអ្នកត្រូវការការធ្វើដំណើរទៅ៖

- វេជ្ជបណ្ឌិតរបស់អ្នក
- ពេទ្យធ្មេញរបស់អ្នក។
- អ្នកប្រឹក្សាយោបល់។
- ឱសថស្ថានទៅទទួលថ្នាំ។
- ជ្រើសរើសឧបករណ៍វេជ្ជសាស្ត្រដែលប្រើប្រាស់បានយូរ ដូចជារទេះរុញ ឬឧបករណ៍ជំនួយការដើរ។
- ការថែទាំបន្ត ដូចជាការលាងឈាម។
- ផ្ទះរបស់អ្នកពីមន្ទីរពេទ្យ។

## ការណែនាំបន្ថែមសម្រាប់ការប្រើប្រាស់សេវាកម្មនេះ។

- អ្នកអាចនាំមនុស្សម្នាក់មកជាមួយអ្នក។ អ្នកមកជាមួយត្រូវតែមានអាយុ 18 ឆ្នាំឡើងទៅ។
- ប្រសិនបើអ្នកត្រូវការរទេះរុញ ឬកៅអីរថយន្តសម្រាប់ការជិះ អ្នកត្រូវតែមានវាដោយខ្លួនឯង។
- សូមត្រៀមខ្លួនជាស្រេចនៅម៉ោងកំណត់មកទទួល។ អ្នកបើកបរត្រូវបានតម្រូវឱ្យរង់ចាំត្រឹមតែ 15 នាទីប៉ុណ្ណោះ ហួសពីម៉ោងទៅយករបស់អ្នក។ អ្នកបើកបរ Rideshare នឹងរង់ចាំតែ 5 នាទីប៉ុណ្ណោះ ហួសពីម៉ោងទៅយក។
- សូមទូរសព្ទទៅ ModivCare ភ្លាមៗនៅពេលអ្នកដឹងថាដំណើរទស្សនកិច្ចរបស់អ្នកត្រូវបានលុបចោល ឬផ្លាស់ប្តូរទៅកាលបរិច្ឆេទផ្សេងទៀត។ វានឹងជួយយើងក្នុងការបម្រើសមាជិកផ្សេងទៀតបានកាន់តែប្រសើរ។
- ប្រសិនបើអ្នកមិនដឹងថាពេលណាដែលការពិនិត្យមើលការថែទាំសុខភាពរបស់អ្នកនឹងត្រូវបញ្ចប់ សូមទូរសព្ទទៅ **1-855-253-6863**។ ចុចជម្រើស 1 ។ យើងនឹងជួយអ្នករៀបចំការធ្វើដំណើរទៅផ្ទះរបស់អ្នក។



## សូមត្រៀមព័ត៌មាននេះ នៅពេលអ្នកកក់ការធ្វើដំណើរ៖

- លេខសម្គាល់ខ្លួន (ID) សមាជិកគម្រោងសុខភាព។
- ឈ្មោះនិងអាសយដ្ឋានរបស់វេជ្ជបណ្ឌិត។
- កាលបរិច្ឆេទនិងពេលវេលាណាត់ជួប។
- ពេលវេលា និងអាសយដ្ឋានទៅទទួល។

ប្រសិនបើអ្នកមានពាក្យបណ្ដឹង ឬត្រូវការជំនួយដើម្បីដោះស្រាយបញ្ហា សូមទាក់ទងផ្នែកសេវាសមាជិក Health Net ដោយមិនគិតថ្លៃតាមលេខ **1-800-675-6110 (TTY: 711)** 24 ម៉ោងក្នុងមួយថ្ងៃ 7 ថ្ងៃក្នុងមួយសប្តាហ៍។

## ដើម្បីកក់ការធ្វើដំណើរ៖

- សូមទូរសព្ទទៅផ្នែកសេវាសមាជិក **Health Net** ដោយមិនគិតថ្លៃតាមលេខ **1-800-675-6110 (TTY: 711)** ហើយជ្រើសរើសជម្រើសការធ្វើដំណើរ។
- សូមទូរសព្ទចន្លោះពីម៉ោង **7** ព្រឹក ដល់ **7** យប់។ ម៉ោងប៉ាស៊ីហ្វិក ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ។
- ប្រសិនបើអ្នកត្រូវការសេវាអ្នកបកប្រែក្នុងអំឡុងពេលធ្វើដំណើរ សូមទូរសព្ទទៅលេខនៅខាងក្រោយបណ្ណសម្គាល់ខ្លួន **(ID)** សមាជិករបស់អ្នកសម្រាប់ជំនួយ។
- សូមកុំទូរសព្ទលើសពី **30** ថ្ងៃមុនពេលទៅពិនិត្យសុខភាពរបស់អ្នក ដើម្បីកក់ការធ្វើដំណើរ។
- ប្រសិនបើអ្នកមិនអាចហៅទូរសព្ទបាន សមាជិកគ្រួសារ អ្នកថែទាំ ឬគ្រូពេទ្យអាចហៅទូរសព្ទជំនួសអ្នកបាន។

## តើអ្នកដឹងទេថាអ្នកអាចទាញយកកម្មវិធី **Modivcare** ដើម្បីកក់ការធ្វើដំណើរបាន?

- ស្កេនកូដ **QR** ដោយប្រើកាមេរ៉ាស្មាតហ្វូន ឬថេប្លេតរបស់អ្នក ដើម្បីស្វែងយល់បន្ថែមអំពីកម្មវិធី **Modivcare** នៅទីនេះ។

ស្កេនខ្ញុំ

Health Net អនុវត្តតាមច្បាប់សិទ្ធិស៊ីវិលរបស់រដ្ឋ និងសហព័ន្ធជាធរមាន ហើយមិនរើសអើង មិនរាប់បញ្ចូលមនុស្ស ឬប្រព្រឹត្តលើពួកគេខុសគ្នាៗដោយសារតែពូជសាសន៍ ពណ៌សម្បុរ ដើមកំណើត អាយុ ពិការភាពផ្លូវចិត្ត ពិការភាពរាងកាយ ភេទ (រួមទាំងការមានផ្ទៃពោះ ទំនោរផ្លូវភេទ និងអត្តសញ្ញាណយេនឌ័រ) សាសនា ពូជពង្ស ការកំណត់អត្តសញ្ញាណក្រុមជនជាតិ ស្ថានភាពវេជ្ជសាស្ត្រ ព័ត៌មានសេនេទិច ស្ថានភាពអាពាហ៍ពិពាហ៍ ឬភេទឡើយ។

Health Net ៖

- ផ្តល់ជំនួយ និងសេវាកម្មឥតគិតថ្លៃដល់អ្នកមានពិការភាព ដើម្បីជួយពួកគេប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាពជាមួយពួកយើង ដូចជា៖
  - អ្នកបកប្រែភាសាសញ្ញាដែលមានសមត្ថភាព
  - ព័ត៌មានជាលាយលក្ខណ៍អក្សរជាទម្រង់ផ្សេងៗ (ការព្រីនជាអក្សរខ្នាតធំ ជាសំឡេង ជាទម្រង់អេឡិចត្រូនិកដែលអាចប្រើប្រាស់បាន និងជាទម្រង់ផ្សេងៗទៀត)
- ផ្តល់សេវាកម្មភាសាឥតគិតថ្លៃដល់អ្នកដែលភាសាចម្បងមិនមែនជាភាសាអង់គ្លេស ដូចជា៖
  - អ្នកបកប្រែផ្ទាល់មាត់ដែលមានសមត្ថភាព
  - ព័ត៌មានលាយលក្ខណ៍អក្សរជាភាសាផ្សេងៗ
  - ប្រសិនបើអ្នកត្រូវការសេវាកម្មទាំងនេះ សូមទាក់ទងមជ្ឈមណ្ឌលទំនាក់ទំនងអតិថិជន Health Net តាមរយៈលេខ 1-800-675-6110 (TTY: 711) បម្រើការ 24 ម៉ោងក្នុងមួយថ្ងៃ 7 ថ្ងៃក្នុងមួយសប្តាហ៍ 365 ថ្ងៃក្នុងមួយឆ្នាំ។

តាមការស្នើសុំ ឯកសារនេះអាចត្រូវបានផ្តល់ជូនអ្នកជាអក្សរស្ទាប ការព្រីនជាអក្សរខ្នាតធំ កាសែតជាសំឡេង ឬទម្រង់អេឡិចត្រូនិក។ ដើម្បីទទួលបានច្បាប់ចម្លងជាទម្រង់ផ្សេងទាំងនេះ សូមទូរសព្ទ ឬសរសេរទៅកាន់៖
Health Net
Post Office Box 9103, Van Nuys, California 91409-9103
មជ្ឈមណ្ឌលទំនាក់ទំនងអតិថិជន 1-800-675-6110 (TTY: 711)
California Relay 711

ប្រសិនបើអ្នកជឿថា Health Net បានបរាជ័យក្នុងការផ្តល់សេវាទាំងនេះ ឬមានការរើសអើងក្នុងវិធីមួយផ្សេងទៀតដោយផ្អែកលើពូជសាសន៍ ពណ៌សម្បុរ ដើមកំណើត អាយុ ឬភេទ (រួមទាំងការមានផ្ទៃពោះ ទំនោរផ្លូវភេទ និងអត្តសញ្ញាណយេនឌ័រ) ពិការភាពផ្លូវចិត្ត ពិការភាពរាងកាយ សាសនា ពូជពង្ស ការកំណត់អត្តសញ្ញាណក្រុមជនជាតិ ស្ថានភាពវេជ្ជសាស្ត្រ ព័ត៌មានសេនេទិច ស្ថានភាពអាពាហ៍ពិពាហ៍ ឬយេនឌ័រ អ្នកអាចដាក់ពាក្យបណ្តឹងសារទុក្ខទៅកាន់អ្នកសម្របសម្រួល 1557។

អ្នកអាចដាក់ពាក្យបណ្តឹងសារទុក្ខដោយផ្ទាល់ ឬតាមប្រៃសណីយ៍ ទូរសារ ឬអ៊ីមែល។ **អ្នកសម្របសម្រួល 1557** របស់យើងខ្ញុំអាចជួយអ្នកបាន ប្រសិនបើអ្នកត្រូវការជំនួយដើម្បីដាក់ពាក្យបណ្តឹងសារទុក្ខ។

- <u>តាមទូរសព្ទ៖</u> ហៅទៅលេខ 855-577-8234 (TTY: 711)

- <u>តាមទូរសារ៖</u> 1-866-388-1769

- <u>ជាលាយលក្ខណ៍អក្សរ៖</u> សរសេរលិខិតមួយច្បាប់ ហើយផ្ញើទៅកាន់ Health Net 1557 Coordinator, PO Box 31384, Tampa, FL 33631

<u>តាមអេឡិចត្រូនិក៖</u> ផ្ញើអ៊ីមែលទៅ SM_Section1557Coord@centene.com ការជូនដំណឹងនេះមាននៅលើគេហទំព័រ Health Net៖ https://www.healthnet.com/content/healthnet/en_us/disclaimers/legal/non-discrimination-notice-medi-cal.html

អ្នកក៏អាចដាក់ពាក្យបណ្តឹងតវ៉ាស្តីពីសិទ្ធស៊ីវិលជាមួយក្រសួងសេវាថែទាំសុខភាពរដ្ឋ California ការិយាល័យសិទ្ធិស៊ីវិល តាមរយៈទូរសព្ទ ជាលាយលក្ខណ៍អក្សរ ឬតាមប្រព័ន្ធអេឡិចត្រូនិក៖

- <u>តាមទូរសព្ទ៖</u> ហៅទៅលេខ 916-440-7370។ ប្រសិនបើអ្នកមិនអាចនិយាយ ឬស្តាប់មិនសូវបានល្អទេ សូមទូរសព្ទទៅ 711។

- ដោយលិខិតអក្សរ៖ បំពេញទម្រង់ពាក្យបណ្តឹងតវ៉ា ឬសរសេរលិខិតមួយច្បាប់ រួចផ្ញើទៅ Deputy Director, Office of Civil Rights, Department of Health Care Services, Office of Civil Rights, P.O. Box 997413, MS 0009, Sacramento, CA 95899-7413.
ទម្រង់បែបបទពាក្យបណ្តឹងតវ៉ាអាចរកបាននៅ
http://www.dhcs.ca.gov/Pages/Language_Access.aspx
- តាមប្រព័ន្ធអេឡិចត្រូនិក៖ ផ្ញើអ៊ីមែលទៅ CivilRights@dhcs.ca.gov

អ្នកក៏អាចដាក់ពាក្យបណ្តឹងតវ៉ាសិទ្ធិស៊ីវិលជាមួយ U.S. Department of Health and Human Services, Office for Civil Rights តាមប្រព័ន្ធអេឡិចត្រូនិក តាមរយៈការិយាល័យសម្រាប់វិបផតថលបណ្តឹងសិទ្ធិស៊ីវិល មាននៅ https://ocrportal.hhs.gov/ocr/portal/lobby.jsf ឬតាមសំបុត្រ ឬទូរសព្ទបានតាមរយៈ៖

U.S. Department of Health and Human Services

200 Independence Avenue, SW

Room 509F, HHH Building

Washington, D.C. 20201

1-800-368-1019, 1-800-537-7697 (TDD)

ទម្រង់បែបបទពាក្យបណ្តឹងតវ៉ាមាននៅ https://www.hhs.gov/ocr/complaints/index.html។

**English:** If you, or someone you are helping, need language services, call 1-800-675-6110 (TTY: 711). Aids and services for people with disabilities, like accessible PDF and large print documents, are also available. These services are at no cost to you.

**Arabic:** إذا كنت أنت أو أي شخص تقوم بمساعدته، بحاجة إلى الخدمات اللغوية، فاتصل بالرقم 1-800-675-6110 (TTY: 711) تتوفر أيضاً المساعدات والخدمات للأشخاص ذوي الإعاقة، مثل الملفات المنقولة (PDF) التي يمكن الوصول إليها والمستندات المطبوعة الكبيرة. تتوفر هذه الخدمات بدون تكلفة بالنسبة لك.

**Armenian:** Եթե դուք կամ որևէ մեկը, ում դուք օգնում եք, ունեն լեզվական օգնության կարիք, զանգահարեք 1-800-675-6110 (TTY՝ 711)։ Հաշմանդամություն ունեցող մարդկանց համար հասանելի են օգնություն և ծառայություններ, ինչպես օրինակ՝ մատչելի PDF և մեծ տպագրությամբ փաստաթղթեր։ Այս ծառայությունները ձեզ համար անվճար են։

**Cambodian:** ប្រសិនបើអ្នក ឬនរណាម្នាក់ដែលអ្នកកំពុងជួយ ត្រូវការសេវាផ្នែកភាសា សូមទូរសព្ទទៅលេខ 1-800-675-6110 (TTY: 711)។ ជំនួយ និងសេវាកម្មផ្សេងៗសម្រាប់អ្នកដែលពិការ ដូចជាទម្រង់ PDF សម្រាប់អ្នកពិការ និងឯកសារព្រីនជាអក្សរខ្នាតធំក៏មានផ្តល់ជូនផងដែរ។ សេវាកម្មទាំងនេះត្រូវបានផ្តល់ជូនអ្នកដោយមិនគិតថ្លៃ។

**Chinese:** 如果您或者您正在帮助的人需要语言服务，请致电1-800-675-6110 (TTY: 711)。还可提供面向残障人士的帮助和服务，例如无障碍 PDF 和大字版文档。这些服务免费为您提供。

**Farsi:** اگر شما یا هر فرد دیگری که به او کمک می‌کنید نیاز به خدمات زبانی دارد، با شمارهٔ 1-800-675-6110 (TTY: 711) تماس بگیرید. کمک‌ها و خدماتی مانند مدارک با چاپ درشت و PDF دسترس‌پذیر نیز برای معلولان قابل عرضه است. این خدمات هزینه‌ای برای شما نخواهد داشت.

**Hindi:** यदि आपको, या जिसकी आप मदद कर रहे हैं उसे, भाषा सेवाएँ चाहिए, तो कॉल करें 1-800-675-6110 (TTY: 711)। विकलांग लोगों के लिए सहायता और सेवाएं, जैसे सुलभ PDF और बड़े प्रिंट वाले दस्तावेज़, भी उपलब्ध हैं। ये सेवाएँ आपके लिए मुफ़्त उपलब्ध हैं।

**Hmong:** Yog hais tias koj, los sis ib tus neeg twg uas koj tab tom pab nws, xav tau cov kev pab cuam txhais lus, hu rau 1-800-675-6110 (TTY: 711). Tsis tas li ntawd, peb kuj tseem muaj cov khoom siv pab thiab cov kev pab cuam rau cov neeg xiam oob qhab tib si, xws li cov ntaub ntawv PDF uas tuaj yeem nkag cuag tau yooj yim thiab cov ntaub ntawv luam tawm uas pom tus niam ntawv loj. Cov kev pab cuam no yog muaj pab yam tsis xam nqi dab tsi rau koj them li.

**Japanese:** ご自身またはご自身がサポートしている方が言語サービスを必要とする場合は、1-800-675-6110 (TTY: 711)までお問い合わせください。障がいをお持ちの方のために、アクセシブルなPDFや大きな文字で書かれたドキュメントなどの補助・サービスも提供しています。これらのサービスは無料で提供されています。

**Korean:** 귀하 또는 귀하가 도와주고 있는 분이 언어 서비스가 필요하시면 1-800-675-6110 (TTY: 711) 번으로 연락해 주십시오. 장애가 있는 분들에게 보조 자료 및 서비스(예: 액세스 가능한 PDF 및 대형 활자 인쇄본)도 제공됩니다. 이 서비스는 무료로 이용하실 수 있습니다.

**Laotian:** ຖ້າທ່ານ, ຫຼື ບຸກຄົນໃດໜຶ່ງທີ່ທ່ານກຳລັງຊ່ວຍເຫຼືອ, ຕ້ອງການບໍລິການແປພາສາ, ໂທ 1-800-675-6110 (TTY: 711). ນອກນັ້ນ, ພວກເຮົາຍັງມີອຸປະກອນຊ່ວຍເຫຼືອ ແລະ ການບໍລິການສຳລັບຄົນພິການອີກດ້ວຍ, ເຊັ່ນ ເອກະສານ PDF ທີ່ສາມາດເຂົ້າເຖິງໄດ້ສະດວກ ແລະ ເອກະສານພິມຂະໜາດໃຫຍ່. ການບໍລິການເຫຼົ່ານີ້ແມ່ນມີໄວ້ຊ່ວຍເຫຼືອທ່ານໂດຍບໍ່ໄດ້ເສຍຄ່າໃດໆ.

**Mien:** Da'faanh Meih, Fai Heuc Meih Haih Tengx, Oix Janx-kaeqv waac gong, Heuc 1-800-675-6110 (TTY: 711). JomcCaux gong Bun Yangh mienh Caux mv fungc, Oix dongh eix PDF Caux Bunh Fiev dimc, Haih yaac kungx nyei. Deix gong Haih buatc Yietc liuz maiv jaax-zinh Bieqc Meih.

**Punjabi:** ਜੇ ਤੁਹਾਨੂੰ, ਜਾਂ ਜਿਸ ਦੀ ਤੁਸੀਂ ਮਦਦ ਕਰ ਰਹੇ ਹੋ, ਨੂੰ ਭਾਸ਼ਾ ਸੇਵਾਵਾਂ ਦੀ ਜ਼ਰੂਰਤ ਹੈ, ਤਾਂ 1-800-675-6110 (TTY: 711) 'ਤੇ ਕਾਲ ਕਰੋ। ਅਪਾਹਜ ਲੋਕਾਂ ਲਈ ਸਹਾਇਤਾ ਅਤੇ ਸੇਵਾਵਾਂ, ਜਿਵੇਂ ਕਿ ਪਹੁੰਚਯੋਗ PDF ਅਤੇ ਵੱਡੇ ਪ੍ਰਿੰਟ ਵਾਲੇ ਦਸਤਾਵੇਜ਼, ਵੀ ਉਪਲਬਧ ਹਨ। ਇਹ ਸੇਵਾਵਾਂ ਤੁਹਾਡੇ ਲਈ ਮੁਫ਼ਤ ਹਨ।

**Russian:** Если вам или человеку, которому вы помогаете, необходимы услуги перевода, звоните по телефону 1-800-675-6110 (TTY: 711). Кроме того, мы предоставляем материалы и услуги для людей с ограниченными возможностями, например документы в специальном формате PDF или напечатанные крупным шрифтом. Эти услуги предоставляются бесплатно.

**Spanish:** Si usted o la persona a quien ayuda necesita servicios de idiomas, comuníquese al 1-800-675-6110 (TTY: 711). También hay herramientas y servicios disponibles para personas con discapacidad, como documentos en letra grande y en archivos PDF accesibles. Estos servicios no tienen ningún costo para usted.

**Tagalog**: Kung ikaw o ang taong tinutulungan mo ay kailangan ng mga serbisyo sa wika, tumawag sa 1-800-675-6110 (TTY: 711). Makakakuha rin ng mga tulong at serbisyo para sa mga taong may mga kapansanan, tulad ng naa-access na PDF at mga dokumentong malaking print. Wala kang babayaran para sa mga serbisyong ito.

**Thai:** หากคุณหรือคนที่คุณช่วยเหลือ ต้องการบริการด้านภาษา โทร 1-800-675-6110 (TTY: 711) นอกจากนี้ยังมีความช่วยเหลือและบริการสำหรับผู้ทุพพลภาพ เช่น PDF ที่เข้าถึงได้และเอกสารที่พิมพ์ขนาดใหญ่ บริการเหล่านี้ไม่มีค่าใช้จ่ายสำหรับคุณ

**Ukrainian:** Якщо вам або людині, якій ви допомагаєте, потрібні послуги перекладу, телефонуйте на номер 1 800 675 6110 (TTY: 711). Ми також надаємо матеріали та послуги для людей з обмеженими можливостями, як-от документи в спеціальному форматі PDF або надруковані великим шрифтом.
Ці послуги для вас безкоштовні.

**Vietnamese:** Nếu quý vị hoặc ai đó mà quý vị đang giúp đỡ cần dịch vụ ngôn ngữ, hãy gọi 1-800-675-6110 (TTY: 711). Chúng tôi cũng có sẵn các trợ giúp và dịch vụ dành cho người khuyết tật, như tài liệu dạng bản in khổ lớn và PDF có thể tiếp cận được. Quý vị được nhận các dịch vụ này miễn phí.

Health Net Community Solutions, Inc. គឺជាបុត្រសម្ព័ន្ធមួយរបស់ Health Net, LLC.។ Health Net គឺជាសញ្ញាសម្គាល់ពាណិជ្ជកម្មដែលបានចុះបញ្ជីរបស់ Health Net, LLC.។ រក្សាសិទ្ធិគ្រប់យ៉ាង។

© 2024 ដោយ ModivCare។ រក្សាសិទ្ធិគ្រប់យ៉ាង។

BKT065894DP00 (1/25)